ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា

នាព្រឹកថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ**) បានដឹកនាំកិច្ចប្រជុំ **គ.ស.ហ** ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបានពិភាក្សាលើរបៀបវារៈដូចខាងក្រោម÷

១. វិធានការចាំបាច់ដើម្បីលើកស្ទួយវិស័យទេសចរណ៍,
២. ការជំរុញលើកទឹកចិត្តដល់គោលនយោបាយទេសចរណ៍ផ្ទះទី ២ សម្រាប់ទេសចរវ័យចំណាស់ និង
៣. ការរៀបចំផែនការមេអភិវឌ្ឍខេត្តមណ្ឌលគិរី ឱ្យទៅជាតំបន់ទេសចរណ៍សមាហរណពិសេស និងការរៀបចំផែនការមេ និងផែនការសកម្មភាពជំរុញអភិវឌ្ឍខេត្តកែប ទៅជាតំបន់ទេសចរណ៍ធម្មជាតិ ។

ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដែលជាចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិឱ្យកាន់តែរឹងមាំ និងនិរន្តរភាព និងដោយផលិតផលទេសចរណ៍កម្ពុជានៅមានកម្រិត បើធៀបនឹងប្រទេសជិតខាងក្នុងតំបន់, កម្ពុជាត្រូវធ្វើពិពិធកម្មផលិតផលទេសចរណ៍ជាចាំបាច់ សំដៅលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យទេសចរណ៍កម្ពុជា ជាពិសេ ទេសចរណ៍បែបវប្បធម៌ និងធម្មជាតិ ដែលជាផលិតផលឈានមុខរបស់កម្ពុជា ។ ក្រសួងទេសចរណ៍ បានរៀបចំវិធានការក្នុងការលើកស្ទួយវិស័យទេសចរណ៍កម្ពុជា តាមរយៈ ការអភិវឌ្ឍផលិតផលទេសចរណ៍, ការលើកកម្ពស់សេវាមួយស្តង់ដារមួយ, បុគ្គលិកម្នាក់ជំនាញមួយ និង ទេសចរណ៍វៃឆ្លាត (Smart Tourism) ជាដើម ។ លើកកម្ពស់សេវាមួយស្តង់ដារមួយ គឺជាបទដ្ឋាននៃសេវាទេសចរណ៍ឱ្យស្របតាមស្តង់ដារអាស៊ាន ស្របពេលដែលទស្សនវិស័យនៃបុគ្គលិកម្នាក់ជំនាញមួយ ជាការគិតគូរថ្មី សំដៅរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅកម្ពុជា តាមរយៈការកើនចំនួន និងគុណភាពនៃសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ។ ជាមួយគ្នានេះ, ការអភិវឌ្ឍវិស័យទេសចរណ៍វៃឆ្លាត សំដៅដល់ធ្វើឌីជីថលរូបនីយកម្ម (Digitalization) ក្នុងដំណើរការនៃការគ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍, ការធ្វើដំណើរ, បដិសណ្ឋារកិច្ច, និងឧស្សាហកម្មម្ហូប-អាហារ ជាដើម ។ វិធានការខាងលើត្រូវគាំទ្រដោយអភិក្រម ៤ ដែលជាគោលការណ៍គ្រឹះនៃផែនការអភិវឌ្ឍវិស័យទេសចរណ៍ រួមមាន ការពង្រឹងយន្តការស្ថាប័ន, ការផ្សព្វផ្សាយក្នុងប្រទេស និងក្រៅប្រទេស និងការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ ។

ជាលទ្ធផល, អង្គប្រជុំ បានគាំទ្រចំពោះវិធានការដែលបានដាក់ចេញដោយក្រសួងទេសចរណ៍ និងបានស្នើឲ្យគ្រប់ក្រសួង-ស្ថាប័ន និងសមត្ថកិច្ចពាក់ព័ន្ធ ចូលរួម និងគាំទ្រ នៅគ្រប់យន្តការទាំងអស់ រួមទាំង យន្តការគណៈកម្មាធិការ និងក្រុមការងារដែលមានជាធរមាន ដើម្បីសម្រួលដល់ការប្រតិបត្តិអភិវឌ្ឍវិស័យទេសចរណ៍មានប្រសិទ្ធិភាពខ្ពស់ និងប្រកបដោយស័ក្តិសិទ្ធភាព ។

តាមស្មារតីនៃអនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីតំបន់ទេសចរណ៍ពិសិដ្ឋ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៩ កន្លងមក, អង្គប្រជុំ គាំទ្រចំពោះគម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ និងបានលើកទឹកចិត្តឱ្យមានការសិក្សាស៊ីជម្រៅមុននឹងឈានដល់ការអនុវត្តគម្រោងពាក់ព័ន្ធនានា ដោយមានការគិតគូរបង្កើតជាយន្តការ និងនីតិវិធីជាកញ្ចប់ សំដៅសម្រួល និងបង្កើនប្រសិទ្ធភាពនៃដំណើរការអនុវត្តគម្រោងតំបន់ទេសចរណ៍ពិសិដ្ឋ ជាពិសេស គម្រោងទេសចរណ៍ផ្ទះទី ២ សម្រាប់ទេសចរវ័យចំណាស់ ។ ការអនុវត្ត គួរចាប់ផ្តើមពីកម្រិតសាកល្បងមុននឹងឈានដល់ទ្រង់ទ្រាយធំ ។ ក្នុងស្មារតីនេះ, ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងបន្តចូលរួមចំណែកផ្តល់កិច្ចសហការ និងការគាំទ្រក្នុងគ្រប់ទិដ្ឋភាព រាប់ទាំងហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ ទទួលបានជោគជ័យ ។

ចំពោះការផ្តួចផ្តើមក្នុងការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខេត្តអាទិភាពនានា, អង្គប្រជុំបានពិភាក្សា និងឯកភាពជាគោលការណ៍ថា ត្រូវមានការរៀបចំផែនការមេអភិវឌ្ឍន៍ និងផែនការវិនិយោគឱ្យបានគ្រប់ជ្រុងជ្រោយ ។ ផែនការមេ នឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពអាជីវកម្មគាំទ្រ ជាពិសេស សហគ្រាសធុនតូច និងមធ្យម ។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា, គណៈកម្មាការអភិឌ្ឍន៍វិស័យទេសចរណ៍ និងក្រុមការងារពាក់ព័ន្ធដ៏ផ្សេងទៀត នឹងបន្តជ្រោមជ្រែងជំរុញ និងគាំទ្រ លើវិធានការ និងផែនការនៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យអស់ពីសក្តានុពល ក្នុងគោលដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងវិស័យទេសចរណ៍កម្ពុជា ។